**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រសួងការបរទេស**
**និងសហប្រតិបត្តិការអន្តរជាតិ**

# សេចក្តីប្រកាសព័ត៌មាន
# លទ្ធផលនៃសន្និសីទក្រោយកិច្ចប្រជុំរដ្ឋមន្ត្រីការបរទេសអាស៊ាន ជាមួយប្រទេសកាណាដា និងនូវែលសេឡង់ និង ជំនួបទ្វេភាគីជាមួយលោកជំទាវរដ្ឋមន្ត្រីការបរទេស នៃប្រទេសនូវែលសេឡង់ ថ្ងៃទី០៥ ខែសីហា ឆ្នាំ២០២១ តាមប្រព័ន្ធវីដេអូ

នៅថ្ងៃទី ០៥ ខែសីហា ឆ្នាំ២០២១ ឯកឧត្តមឧបនាយករដ្ឋមន្ត្រី **ប្រាក់ សុខុន** រដ្ឋមន្ត្រីការបរទេស និងសហប្រតិបត្តិការអន្តរជាតិ បានអញ្ជើញ ចូលរួមក្នុងសន្និសីទក្រោយកិច្ចប្រជុំរដ្ឋមន្ត្រីការបរទេសអាស៊ានជាមួយប្រទេសកាណាដា និងនូវែលសេឡង់។ នៅថ្ងៃដដែលនេះ **ឯកឧត្តមឧបនាយករដ្ឋមន្ត្រី** មានជំនួបទ្វេភាគីជាមួយលោកជំទាវ **ណាណៃយ៉ា ម៉ាហ៊ូតា** (Nanaia Mahuta) រដ្ឋមន្ត្រីការបរទេស និងពាណិជ្ជកម្ម នៃប្រទេសនូវែលសេឡង់ តាមប្រព័ន្ធវីដេអូ នៅមុនសន្និសីទក្រោយកិច្ចប្រជុំរដ្ឋមន្ត្រីការបរទេសអាស៊ានជាមួយនូវែលសេឡង់ និងបានអញ្ជើញចូលរួមក្នុងពិធីផ្តល់ឋានៈភាពជាដៃគូសន្ទនារបស់អាស៊ាន ឱ្យទៅចក្រភពអង់គ្លេស។

## សន្និសីទក្រោយកិច្ចប្រជុំរដ្ឋមន្ត្រីការបរទេសអាស៊ានជាមួយកាណាដា

កិច្ចប្រជុំបានសាទរចំពោះសារៈសំខាន់ដែលកំពុងកើនឡើងនៃទំនាក់ទំនងអាស៊ាន-កាណាដា និងបានប្តេជ្ញាសម្រេចឱ្យបានលទ្ធផលល្អប្រសើរពីផែនការសកម្មភាពដើម្បីអនុវត្តសេចក្តីថ្លែងការណ៍រួម ស្តីពីការលើកកម្ពស់ភាពជាដៃគូអាស៊ាន-កាណាដា (២០២១-២០២៥)។ រដ្ឋមន្ត្រីការបរទេសអាស៊ាន បានស្វាគមន៍ចំណាប់អារម្មណ៍របស់កាណាដាក្នុងការលើកកម្ពស់ទំនាក់ទំនងជាមួយអាស៊ាន ទៅជាភាពជាដៃគូយុទ្ធសាស្ត្រ ហើយនិងបានរំពឹងដល់ការរៀបចំឱ្យមានសកម្មភាពរួមគ្នា នៅទូទាំងសសរស្តម្ភទាំងបី ដើម្បីប្រារព្ធខួបលើកទី៤៥ នៃភាពជាដៃគូសន្ទនាអាស៊ាន-កាណាដា នៅក្នុងឆ្នាំ២០២២។ រដ្ឋមន្ត្រីការបរទេសអាស៊ានបានសម្តែងនូវសុទិដ្ឋិនិយមថា ការចរចារលើកិច្ចព្រមព្រៀងពាណិជ្ជកម្មសេរីអាស៊ាន-កាណាដា អាចនឹងត្រូវបានដាក់ឱ្យដំណើរការនៅក្នុងឆ្នាំ២០២១ ហើយនឹងក្លាយទៅជាព្រឹត្តិការណ៍ដ៏ធំមួយនៅក្នុងពេលនោះ។

សម្រាប់ការប្រយុទ្ធប្រឆាំងនឹងជំងឺកូវីដ-១៩ រដ្ឋមន្ត្រីការបរទេសអាស៊ានបានកោតសរសើរយ៉ាងខ្លាំងចំពោះកិច្ចសហប្រតិបត្តិការរបស់កាណាដា ក្នុងការអនុវត្តក្របខ័ណ្ឌស្តារឡើងវិញគ្រប់ជ្រុងជ្រោយរបស់



អាសយដ្ឋាន: លេខ ៣ វិថី **សម្តេច ហ៊ុន សែន**
សង្កាត់ទន្លេបាសាក់ ខ័ណ្ឌចំការមន
រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា
ទូរស័ព្ទ : (855) 23 216 122
ទូរសារ : (855) 23 216 141, 023 213 341
អ៊ីម៉ែល : mfaic@mfaic.gov.kh

អាស៊ាន។ រដ្ឋមន្ត្រីការបរទេសអាស៊ាន បានស្វាគមន៍ការរួមចំណែករបស់កាណាដា ដែលបានផ្តល់ទឹកប្រាក់ចំនួន ៣,៥លានដុល្លារកាណាដា ដល់មូលនិធិអាស៊ានឆ្លើយតបទៅនឹងជំងឺកូវីដ-១៩ និងបានផ្តល់សម្លៀកបំពាក់ការពារ (PPEs) ក្នុងទំហំទឹកប្រាក់ ៤,៥លានដុល្លារកាណាដា ដើម្បីគាំទ្រដល់ការឆ្លើយតបតំបន់។

សម្រាប់ការកំណត់ទិសដៅអនាគតនៃទំនាក់ទំនងសន្ទនាអាស៊ាន-កាណាដា កាណាដាបានអះអាងជាថ្មីអំពីការគាំទ្រមជ្ឈភាពអាស៊ាននៅក្នុងនិម្មាបនកម្ម និងបានប្តេជ្ញាចិត្តពង្រឹងបន្ថែមទៀតនូវភាពជាដៃគូនៅក្នុងវិស័យនយោបាយ-សន្តិសុខ សេដ្ឋកិច្ច និងសង្គម-វប្បធម៌ ដូចដែលមានចែងក្រោមទស្សនៈវិស័យអាស៊ានស្តីពីឥណ្ឌូ-ប៉ាស៊ីហ្វិក (AOIP) រួមមាន កិច្ចសហប្រតិបត្តិការលំហសមុទ្រ ការតភ្ជាប់ គោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាពរបស់អង្គការសហប្រជាជាតិឆ្នាំ២០៣០។ កិច្ចប្រជុំក៏បានសង្កត់ធ្ងន់ផងដែរលើសារៈសំខាន់នៃកិច្ចសហប្រតិបត្តិការអាស៊ាន-កាណាដា នៅក្នុងវិស័យផ្សេងៗ រួមមាន កិច្ចខិតខំប្រឹងប្រែងស្តារឡើងវិញក្រោយជំងឺរាតត្បាត សុខភាពសាធារណៈនិងការអប់រំ ពាណិជ្ជកម្មនិងការវិនិយោគដោយផ្តោតការយកចិត្តទុកដាក់លើសេដ្ឋកិច្ចឌីជីថល ការប្រែប្រួលអាកាសធាតុនិងការគ្រប់គ្រងគ្រោះមហន្តរាយ ការលើកកម្ពស់និងការការពារសិទ្ធិស្ត្រី កុមារ និងពលករចំណាកស្រុក និងការបង្រួមគម្លាតអភិវឌ្ឍន៍។

នៅក្នុងកិច្ចប្រជុំ ឯកឧត្តមឧបនាយករដ្ឋមន្ត្រី **ប្រាក់ សុខុន** បានស្វាគមន៍សំណើរបស់កាណាដាក្នុងការរៀបចំកិច្ចប្រជុំកំពូលរំលឹកខួប នៅឆ្នាំ២០២២ ដើម្បីអបអរសាទរខួបលើកទី៤៥ នៃភាពជាដៃគូសន្ទនាអាស៊ាន-កាណាដា។ **ឯកឧត្តមឧបនាយករដ្ឋមន្ត្រី** បានលើកទឹកចិត្តឱ្យខិតខំប្រឹងប្រែងបន្ថែមទៀត ដើម្បីឆ្ពោះទៅសម្រេចបានឆាប់រហ័សនូវកិច្ចព្រមព្រៀងពាណិជ្ជកម្មសេរីអាស៊ាន-កាណាដា ដើម្បីអាចក្តាប់យកប្រកបដោយប្រសិទ្ធភាពនូវសក្តានុពលយ៉ាងធំធេងសម្រាប់តំបន់ទាំងពីរ។ **ឯកឧត្តម** ក៏បានអំពាវនាវឱ្យមានកិច្ចសហប្រតិបត្តិការកាន់តែទូលំទូលាយលើរបៀបវារៈ ស្តីពីស្ត្រី សន្តិភាព សន្តិសុខ និងការថែរក្សាសន្តិភាពតាមរយៈកម្មវិធីកសាងសមត្ថភាព និងគាំទ្របន្ថែមទៀតដល់មជ្ឈមណ្ឌលតំបន់អាស៊ានសម្រាប់សកម្មភាពមីន (ARMAC)។ **ឯកឧត្តមឧបនាយករដ្ឋមន្ត្រី** បានគូសបញ្ជាក់អំពីផែនការយុទ្ធសាស្ត្រប្រែប្រួលអាកាសធាតុកម្ពុជា ក្នុងរយៈពេល១០ឆ្នាំ (២០១៤-២០២៣) និងបានសម្តែងនូវការកោតសរសើរសម្រាប់ការគាំទ្ររបស់កាណាដាចំពោះអាស៊ាន តាមរយៈមូលនិធិអាកាសធាតុកាណាដាសម្រាប់វិស័យឯកជននៅក្នុងតំបន់អាស៊ី និងមូលនិធិសម្រាប់ប្រទេសមានការអភិវឌ្ឍតិចតួច។ ឆ្លៀតក្នុងឱកាសនោះ **ឯកឧត្តមឧបនាយករដ្ឋមន្ត្រី** បានថ្លែងអំណរគុណកាណាដាសម្រាប់ការគាំទ្រដល់កម្ពុជាក្នុងវិស័យអប់រំនិងការអភិវឌ្ឍធនធានមនុស្ស និងកិច្ចខិតខំប្រឹងប្រែងក្នុងការធ្វើសមាហរណកម្មតំបន់។

**<u>សន្និសីទក្រោយកិច្ចប្រជុំរដ្ឋមន្ត្រីការបរទេសអាស៊ានជាមួយនូវែលសេឡង់</u>**

កិច្ចប្រជុំត្រូវបានអញ្ជើញធ្វើជាសហប្រធានដោយ **ឯកឧត្តម ប្រាក់ សុខុន** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីការបរទេស និងសហប្រតិបត្តិការអន្តរជាតិនៃព្រះរាជាណាចក្រកម្ពុជា ក្នុងនាមជាប្រទេសសម្របសម្រួលទំនាក់ទំនងដៃគូសន្ទនាអាស៊ាន-នូវែលសេឡង់ និង**លោកជំទាវ ណាណៃយ៉ា ម៉ាហ៊ូតា** (Nanaia Mahuta) រដ្ឋមន្ត្រីការបរទេស និងពាណិជ្ជកម្មនៃប្រទេសនូវែលសេឡង់។

កិច្ចប្រជុំបានរំលឹកអំពីការរៀបចំប្រកបដោយភាពជោគជ័យនូវកិច្ចប្រជុំកំពូលរំលឹកខួបអនុស្សាវរីយ៍អាស៊ាន-នូវែលសេឡង់ កាលពីខែវិច្ឆិកា ឆ្នាំ២០២០ តាមប្រព័ន្ធវីដេអូ ដើម្បីអបអរសាទរខួបលើកទី៤៥

នៃទំនាក់ទំនងសន្ទនាអាស៊ាន-នូវែលសេឡង់។ ដើម្បីរក្សាបាននូវសន្ទុះវិជ្ជមាននៅក្នុងទំនាក់ទំនងអាស៊ាន និងនូវែលសេឡង់ កិច្ចប្រជុំបានឯកភាពពន្លឿនការអនុវត្តការប្តេជ្ញាចិត្តរបស់ខ្លួន ចំពោះសេចក្តីប្រកាសចក្ខុវិស័យរួមរបស់ថ្នាក់ដឹកនាំអាស៊ាន-នូវែលសេឡង់ ស្តីពីខួបអនុស្សាវរីយ៍លើកទី៤៥ នៃទំនាក់ទំនងដៃគូសន្ទនាអាស៊ាន-នូវែលសេឡង់៖ កេរដំណែលនៃភាពជាដៃគូ អនាគតរួមគ្នា។ កិច្ចប្រជុំបានសម្តែងការពេញចិត្តចំពោះវឌ្ឍនភាពនៃការអនុវត្តផែនការសកម្មភាពសំរាប់ពង្រឹងភាពជាដៃគូយុទ្ធសាស្ត្រអាស៊ាន-នូវែលសេឡង់ (២០២១-២០២៥) ស្របតាមមូលបទគន្លឹះដែលបានឯកភាព «សន្តិភាព វិបុលភាពប្រជាជន និងភពផែនដី» ជាមួយនឹងទស្សនៈក្នុងការរួមចំណែកដើម្បីសម្រេចឱ្យបាននូវចក្ខុវិស័យសហគមន៍អាស៊ាន ឆ្នាំ២០២៥។

អាស៊ានបានសម្តែងនូវការកោតសរសើរចំពោះការប្តេជ្ញាចិត្តរបស់ប្រទេសនូវែលសេឡង់ ក្នុងការពង្រឹងការផ្លាស់ប្តូររវាងប្រជាជននិងប្រជាជន តាមរយៈការផ្តល់អាហារូបករណ៍ ការអប់រំ និងបណ្តុះបណ្តាលបច្ចេកទេស និងវិជ្ជាជីវៈ (TVET) ព្រមទាំងកម្មវិធីបណ្តុះបណ្តាលជំនាញរយៈពេលខ្លី។ ក្នុងន័យនេះ អាស៊ាន បានថ្លែងអំណរគុណដល់ប្រទេសនូវែលសេឡង់ សម្រាប់ការបន្តផ្តល់កម្មវិធីបណ្តុះបណ្តាលរយៈពេលខ្លី ស្តីពីការគ្រប់គ្រងគ្រោះមហន្តរាយ តាមរយៈកម្មវិធី AHA Center Executive (ACE) ក៏ដូចជាជំនួយដល់ការអភិវឌ្ឍវិស័យកសិកម្មដែលឆ្លាតធន់នឹងអាកាសធាតុ នៅក្នុងប្រទេសជាសមាជិកអាស៊ាន ក្នុងរយៈពេល ៥ឆ្នាំខាងមុខ តាមរយៈសម្ព័ន្ធភាពស្រាវជ្រាវសកល ស្តីពីឧស្ម័នផ្ទះកញ្ចក់។

កិច្ចប្រជុំបានស្វាគមន៍ការចាប់ផ្តើមកិច្ចចរចាដើម្បីលើកកម្ពស់តំបន់ពាណិជ្ជកម្មសេរីអាស៊ាន-អូស្ត្រាលី-នូវែលសេឡង់ (AANZFTA) និងទន្ទឹងដល់កម្មវិធីគាំទ្រកិច្ចសហប្រតិបត្តិការសេដ្ឋកិច្ចតំបន់ពាណិជ្ជកម្មសេរីអាស៊ាន-អូស្ត្រាលី-នូវែលសេឡង់ (AANZFTA) ដែលរហូតមកដល់ពេលនេះបានចូលរួមចំណែកយ៉ាងសំខាន់ក្នុងការលើកកម្ពស់សមត្ថភាពពាណិជ្ជកម្មនិងសេដ្ឋកិច្ចរបស់ប្រទេសជាសមាជិកអាស៊ាន។

កិច្ចប្រជុំបានរំពឹងដល់ការសំរេចឱ្យបានឆាប់នូវកិច្ចព្រមព្រៀងសេវាកម្មអាកាសចរណ៍ក្នុងតំបន់ ដែលមានគុណភាពខ្ពស់ រវាងរដ្ឋាភិបាលនៃប្រទេសជាសមាជិកអាស៊ាន និងប្រទេសនូវែលសេឡង់ ដើម្បីផ្តល់នូវបរិយាកាសមួយដែលកាន់តែបើកចំហសម្រាប់ការតភ្ជាប់ផ្លូវអាកាស និងដើម្បីជួយសម្រួលឱ្យកាន់តែប្រសើរឡើងដល់ចរាចរប្រជាជន និងទំនិញ។ អាស៊ានបានស្វាគមន៍ដល់ការគាំទ្របន្តរបស់នូវែលសេឡង់សម្រាប់ការអនុវត្តផែនការមេ ស្តីពីការតភ្ជាប់អាស៊ាន (MPAC) ឆ្នាំ២០២៥ ផែនការការងារនៃគំនិតផ្តួចផ្តើមសមាហរណកម្មអាស៊ាន (IAI) ដំណាក់កាលទី៤ និងបណ្តាញទីក្រុងឆ្លាតអាស៊ាន (ASCN) និងការប្តេជ្ញាចិត្តក្នុងការលើកកម្ពស់កិច្ចសហប្រតិបត្តិការក្នុងវិស័យសេដ្ឋកិច្ចឌីជីថល ពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិក កសិកម្មដែលឆ្លាតធន់នឹងអាកាសធាតុ ការសម្រួលធុរកិច្ចនិងខ្សែប្រវ៉ាក់ផ្គត់ផ្គង់ និងសហគ្រាសមីក្រូ តូច និងមធ្យម (MSMEs)។

កិច្ចប្រជុំបានថ្លែងអំណរគុណកម្ពុជា ក្នុងនាមជាប្រទេសសម្របសម្រួលដែលនឹងចប់អាណត្តិ ដែលបានកាច់ចង្កូតដឹកនាំភាពជាដៃគូអាស៊ាន-នូវែលសេឡង់ ឱ្យសម្រេចបានលទ្ធផលប្រកបដោយផ្លែផ្កា ក្នុងរយៈពេលបីឆ្នាំចុងក្រោយនេះ (២០១៨-២០២១) និងបានសម្តែងនូវទំនុកចិត្តថាទំនាក់ទំនងសន្ទនាអាស៊ាន-នូវែលសេឡង់ នឹងកាន់តែលូតលាស់ក្រោមការដឹកនាំរបស់ប្រទេសប្រ៊ុយណេដារូសាឡាម ក្នុងនាមជាប្រទេសសម្របសម្រួលបន្ទាប់ សម្រាប់រយៈពេលបីឆ្នាំខាងមុខ។

**<u>ជំនួបទ្វេភាគីជាមួយលោកជំទាវរដ្ឋមន្ត្រីការបរទេស និងពាណិជ្ជកម្មនៃប្រទេសនូវែលសេឡង់</u>**

នៅមុនសន្និសីទក្រោយកិច្ចប្រជុំរដ្ឋមន្ត្រីការបរទេសអាស៊ានជាមួយប្រទេសនូវែលសេឡង់ **ឯកឧត្តមឧបនាយករដ្ឋមន្ត្រី** មានជំនួបទ្វេភាគីជាមួយលោកជំទាវ **ណាណៃយ៉ា ម៉ាហ៊ូតា** (Nanaia Mahuta) រដ្ឋមន្ត្រីការបរទេស និងពាណិជ្ជកម្មនៃប្រទេសនូវែលសេឡង់ តាមប្រព័ន្ធវីដេអូ។ រដ្ឋមន្ត្រីការបរទេសទាំងពីរ បានផ្លាស់ប្តូរទស្សនៈគ្នា និងឈានដល់ការឯកភាពលើកិច្ចសហប្រតិបត្តិការក្នុងវិស័យនានា ដើម្បីពង្រឹងបន្ថែមទៀតនូវទំនាក់ទំនងដៃគូសន្ទនាអាស៊ាន-នូវែលសេឡង់ និងដោះស្រាយបញ្ហាតំបន់ និងអន្តរជាតិ ដែលជាការបារម្ភ និងចំណាប់អារម្មណ៍រួម។

លោកជំទាវ **ណាណៃយ៉ា ម៉ាហ៊ូតា** បានសម្តែងការកោតសរសើរដល់កម្ពុជា ដែលបានធ្វើការងារសម្របសម្រួលយ៉ាងល្អប្រសើរ ក្នុងនាមជាប្រទេសសម្របសម្រួលទំនាក់ទំនងដៃគូសន្ទនាអាស៊ាន-នូវែលសេឡង់ ចាប់តាំងពីខែសីហា ឆ្នាំ២០១៨ មក។ **លោកជំទាវ** ក៏បានអបអរសាទរផងដែរដល់ប្រទេសកម្ពុជា ចំពោះសមិទ្ធផល និងកិច្ចខិតខំប្រឹងប្រែងរបស់ប្រទេសកម្ពុជា ក្នុងយុទ្ធនាការចាក់វ៉ាក់សាំង និងការគាំពារសង្គម ក្នុងអំឡុងពេលនៃការរាតត្បាតនៃជំងឺកូវីដ-១៩។

**ឯកឧត្តមឧបនាយករដ្ឋមន្ត្រី** បានថ្លែងអំណរគុណដល់ប្រទេសនូវែលសេឡង់ ដែលបានផ្តល់ជំនួយដល់ប្រទេសកម្ពុជា រួមមានកម្មវិធីបណ្តុះបណ្តាលភាសា ដើម្បីគាំទ្រដល់ការធ្វើជាប្រធានអាស៊ានរបស់កម្ពុជា នៅឆ្នាំ២០២២ សកម្មភាពបោសសំអាតមីន និងកម្មវិធីការអប់រំ និងបណ្តុះបណ្តាលបច្ចេកទេស និងវិជ្ជាជីវៈ (TVET) ដល់ស្ត្រីដែលបានបាត់បង់ការងារដោយសារជំងឺរាតត្បាតកូវីដ-១៩។

**<u>ពិធីផ្តល់ឋានៈភាពជាដៃគូសន្ទនារបស់អាស៊ាន ឱ្យទៅចក្រភពអង់គ្លេស</u>**

ឯកឧត្តមឧបនាយករដ្ឋមន្ត្រី **ប្រាក់ សុខុន** បានអញ្ជើញចូលរួមក្នុងពិធីផ្តល់ឋានៈភាពជាដៃគូសន្ទនារបស់អាស៊ាន ឱ្យទៅចក្រភពអង់គ្លេស។ **ឯកឧត្តម** រួមនិងរដ្ឋមន្ត្រីការបរទេសអាស៊ានផ្សេងទៀត បានធ្វើជាសាក្សីលើការចុះហត្ថលេខាលើលិខិតដែលនឹងចូលជាធរមាន ដោយអគ្គលេខាធិការអាស៊ាន និងឯកឧត្តម **ដូមីនិក រ៉ាអាប់** (Dominic Raab) រដ្ឋមន្ត្រីការបរទេស កំមិនវែល និងអភិវឌ្ឍន៍នៃចក្រភពអង់គ្លេស។ នៅក្នុងពិធី ឯកឧត្តម **ដូមីនិក រ៉ាអាប់** បានអះអាងថា ចក្រភពអង់គ្លេស ជាប្រទេសទី១ ដែលត្រូវបានផ្តល់ឋានៈភាពជាដៃគូសន្ទនារបស់អាស៊ានក្នុងរយៈពេល២៥ឆ្នាំមកនេះ ប្តេជ្ញាចិត្តយ៉ាងពេញលេញក្នុងការគាំទ្រដល់កិច្ចខិតខំប្រឹងប្រែងកសាងសហគមន៍អាស៊ាន ដោយឈរលើគោលការណ៍ និងបំណងប្រាថ្នារួម សម្រាប់សន្តិភាព សន្តិសុខ និងវិបុលភាពនៅក្នុងតំបន់។ ឯកឧត្តម **ដូមីនិក រ៉ាអាប់** បានសន្យាពង្រឹងកិច្ចសហប្រតិបត្តិការបន្ថែមទៀតជាមួយអាស៊ាន នៅក្នុងការឆ្លើយតបនឹងជំងឺរាតត្បាតកូវីដ-១៩ និងការស្តារសេដ្ឋកិច្ច-សង្គមឡើងវិញ លើកកម្ពស់ប្រព័ន្ធពាណិជ្ជកម្មពហុភាគី ការអប់រំវិទ្យាសាស្ត្រនិងបច្ចេកវិទ្យា ការប្រែប្រួលអាកាសធាតុនិងថាមពលស្អាត ការដោះស្រាយសន្តិសុខអ៊ិនធឺរ-ណែត និងបញ្ហាប្រឈមផ្សេងទៀតនៅក្នុងតំបន់ និងសកលលោក ដែលជាការបារម្ភរួមគ្នា។ **ឯកឧត្តម ដាតូ អ៊ីរីវ៉ាន់ ពើហ៊ីន យូស៊ូហ៍** រដ្ឋមន្ត្រីការបរទេសព្រុយណេដារ៉ូស្សាឡាម ដែលជាប្រធានអាស៊ាន បានស្វាគមន៍ចក្រភពអង់គ្លេស ក្លាយជាដៃគូសន្ទនាទី១១ របស់អាស៊ាន និងការប្តេជ្ញាចិត្តរបស់អង់គ្លេស ដើម្បីទទួលបានផលប្រយោជន៍មុតមាំ និងទៅវិញទៅមក ពីភាពជាដៃជាមួយអាស៊ាន។

ថ្ងៃសុក្រ ១៣រោច ខែទុតិយាសាឍ ឆ្នាំឆ្លូវ ត្រីស័ក ព.ស. ២៥៦៥

រាជធានីភ្នំពេញ ថ្ងៃទី៦ ខែសីហា ឆ្នាំ២០២១